ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

សាលាភូមិន្ទរដ្ឋបាល

លេខ...១៥៧...ស.ភ.រ

# សេចក្ដីជូនដំណឹង

អនុលោមតាមសេចក្ដីសម្រេចលេខ ២៦០៨ មស.សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ ស្ដីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៩ សាលាភូមិន្ទរដ្ឋបាល សូមជូនដំណឹងដល់បេក្ខជនទាំងពីរភេទជានិស្សិត និងមន្ត្រីរាជការ អំពីការជ្រើសរើសសិស្សមន្ត្រីក្រមការចំនួន ១២០នាក់ សម្រាប់ការបណ្ដុះបណ្ដាលក្នុងឆ្នាំ២០២១។ បេក្ខជនដែលមានបំណងចង់ចូលរួមក្នុងការប្រឡងប្រជែងនេះ ត្រូវបំពេញលក្ខខណ្ឌ និងបែបបទដូចខាងក្រោម៖

- បេក្ខជនទាំងពីរភេទជានិស្សិតត្រូវមានអាយុយ៉ាងច្រើនបំផុត២៨ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាទាបបំផុតកម្រិតទុតិយភូមិ បូក២ឆ្នាំ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- បេក្ខជនទាំងពីរភេទជាមន្ត្រីរាជការត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនត្រូវជ្រើសរើសភាសាជាមុនក្នុងការដាក់ពាក្យសម្រាប់ការប្រឡងប្រជែងនេះ
- កាលបរិច្ឆេទបំពេញពាក្យតាមប្រព័ន្ធOnline ចាប់ផ្ដើមពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០តទៅ តាមគេហទំព័រ sms.era.gov.kh ឬអាចមកបំពេញពាក្យសុំប្រឡងតាមប្រព័ន្ធOnline នៅសាលាភូមិន្ទរដ្ឋបាល
- បេក្ខជនសូមភ្ជាប់មកជាមួយនូវរូបថតថ្មី ៤x៦ ចំនួន៤សន្លឹក (ផ្ទៃខាងក្រោយពណ៌ស) និងត្រូវស្កេនឯកសារច្បាប់ដើមចូលក្នុងប្រព័ន្ធOnline រួមមាន៖ សំបុត្រកំណើត, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្របរិញ្ញាបត្ររងឬលិខិតបញ្ជាក់បានបញ្ចប់ការសិក្សាឆ្នាំទី២ដោយជោគជ័យ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។ ដោយឡែកបេក្ខជនជាមន្ត្រីរាជការ ត្រូវភ្ជាប់បន្ថែមប្រកាសតាំងស៊ប់ និងលិខិតបញ្ជាក់បច្ចុប្បន្នភាពពីក្រសួង ស្ថាប័ន
- បេក្ខជនត្រូវភ្ជាប់ឯកសារច្បាប់ដើម និងថតចម្លងដោយមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីយកមកដាក់ពាក្យដោយផ្ទាល់ បន្ទាប់ពីទទួលបានសារអនុម័តតាមប្រព័ន្ធOnline ពីសាលាភូមិន្ទរដ្ឋបាល
- កាលបរិច្ឆេទ នៃការទទួលពាក្យ នឹងចាប់ផ្ដើមពីថ្ងៃ០៧ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៧ម៉ោ៣០នាទី ជាពេលផុតកំណត់
- ការប្រឡងប្រជែងនឹងប្រព្រឹត្តទៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០ រីឯកាលបរិច្ឆេទជាក់ស្ដែង នឹងត្រូវប្រកាសផ្សព្វផ្សាយជូននៅពេលក្រោយតាមរយៈគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល។

<u>បញ្ជាក់</u>៖

- ការដាក់ពាក្យសុំសិទ្ធិប្រឡងតម្លៃ ៤៥.០០០៛(សែសិបប្រាំពាន់រៀលគត់)
- ព័ត៌មានលម្អិតសូមចូលមើលក្នុងគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល www.era.gov.kh ឬទំនាក់ទំនងតាមលេខទូរស័ព្ទ Cellcard: ០៩២ ៥១៣៧២០ និង Smart: ០១៦ ៥២៧៣១០ រៀងរាល់ម៉ោងធ្វើការ។

ថ្ងៃ ព្រហស្បតិ៍ [illegible] ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែសីហា ឆ្នាំ២០២០

**សាលាភូមិន្ទរដ្ឋបាល**

**ចម្លងជូន៖**

- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខៈ ៧៦០៨ មស.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៩

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ


អាសយដ្ឋានៈ (កែងផ្លូវម៉ៃដាលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

- បានឃើញអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.តក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្តីពីការលើកលែងលក្ខខណ្ឌអាយុ និងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល
- យោងតាមស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាលនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

**សម្រេច**

**ប្រការ ១.-**

អនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលសិស្សមន្ត្រីក្រមការលើកទី៩ ចំនួន ១២០នាក់ នៅសាលាភូមិន្ទរដ្ឋបាល ដោយត្រូវធ្វើការជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការនិងនិស្សិត។ បេក្ខជនដែលប្រឡងជាប់នឹងត្រូវរៀនរយៈពេល ១ឆ្នាំ។ កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០២០។

**ប្រការ ២ .-**

**លក្ខខណ្ឌជ្រើសរើស ៖**

- បេក្ខជនទាំងពីរភេទជានិស្សិតត្រូវមានអាយុយ៉ាងច្រើនបំផុត២៨ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាទាបបំផុតកម្រិតទុតិយភូមិ បូក២ឆ្នាំ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- បេក្ខជនទាំងពីរភេទជាមន្ត្រីរាជការត្រូវបានលើកលែងលក្ខខណ្ឌអាយុ។
- ត្រូវមានលិខិតបញ្ជាក់ថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅពេលប្រឡងជាប់ជាស្ថាពរ។
- ត្រូវមានលិខិតពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារបញ្ជាក់ថា មានកាយសម្បទាមាំមួន និងសុខភាពល្អបរិបូរណ៍ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។

បញ្ជីបេក្ខជនដែលអនុញ្ញាតឱ្យចូលធ្វើវិញ្ញាសាប្រឡងប្រជែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**ប្រការ ៣ .-**

វិញ្ញាសាប្រឡងប្រជែងរួមមាន ៖ វិញ្ញាសាសរសេរលើកទី១ និងវិញ្ញាសាសរសេរលើកទី២

ក- **វិញ្ញាសាសរសេរលើកទី១ ៖**

សំណួរពហុចម្លើយ និងអធិប្បាយខ្លី " រយៈពេល ២ម៉ោង៣០នាទី "

**មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២។**

ខ- **វិញ្ញាសាសរសេរលើកទី២ ៖**

១- អធិប្បាយជ្រើសរើស ពាក់ព័ន្ធនឹងចំណេះដឹងទូទៅ (ច្បាប់ រដ្ឋបាល សេដ្ឋកិច្ច វប្បធម៌ទូទៅ) និងសំណួរខ្លីពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ភូមិសាស្ត្រ សីលធម៌ ពលរដ្ឋវិទ្យា អរិយធម៌ និងវប្បធម៌ " រយៈពេល ៣ម៉ោង " មេគុណ ១

២- ភាសាអង់គ្លេស ឬភាសាបារាំង " រយៈពេល ១ម៉ោង ៣០នាទី" មេគុណ ១

**ប្រការ ៤ .-**

វិញ្ញាសាសរសេរត្រូវរក្សាអនាមិកភាព។ វិញ្ញាសានីមួយៗត្រូវកែជាពីរលើក និងត្រូវផ្តល់ពិន្ទុលើ ១០០។

**ប្រការ ៥ .-**

ក្រោយការប្រឡងប្រជែង ប្រធានគណៈមេប្រយោគត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល។ របាយការណ៍នេះ នឹងត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ។

**ប្រការ ៦ .-**

ការទទួលស្គាល់ជាសិស្សមន្ត្រីក្រមការនៃសាលាភូមិន្ទរដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ ក្នុងកំឡុងពេលចូលរៀន សិស្សត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ តាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**ប្រការ ៧ .-**

ក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល នាយកសាលាភូមិន្ទរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។៚.

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ